**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) សហភាពសហព័ន្ធយុវជនកម្ពុជា (សសយក) និងស្ថានីយទូរទស្សន៍អ៊ីធីវី (ETV) រៀបចំកម្មវិធីប្រឡងសម្រស់ឯកវាយនភណ្ឌឆ្នាំ២០១៧ (លើកទី៣) ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣១ ទិវាពលកម្មអន្តរជាតិ ១ ឧសភា ដូចតទៅ៖

**១. ការចែក និងទទួលពាក្យ៖** ចាប់ពី ថ្ងៃទី០៦ ខែមីនា ដល់ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី/ខេត្តទាំង២៥ ឬអាចទាញចេញពីគេហទំព័រ www.mlvt.gov.kh ឬ www.facebook.com/mlvt.gov.kh/ ឬទំនាក់ទំនងតាមទូរសព្ទ៖

- លោកស្រី ជា សុខេន ទូរសព្ទលេខ ០៧៧ ៧០០ ៧២៦ (មណ្ឌលរាជធានីភ្នំពេញ)
- លោក ព្រហ្ម ច័ន្ទវិចិត្រ ទូរសព្ទលេខ ០១៧ ៨៧៨ ៣៣១ (មណ្ឌលខេត្តព្រះសីហនុ)
- លោក គឹម សុចិត្រ ទូរសព្ទលេខ ០៩៧ ៣៥៦៧ ៨៨៨ (មណ្ឌលខេត្តស្វាយរៀង)

**២. វគ្គប្រឡងជម្រុះពាក់កណ្តាលផ្តាច់ព្រ័ត្រ** នឹងប្រព្រឹត្តទៅនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ដោយបែងចែកជា ៣មណ្ឌលគឺ៖

-មណ្ឌលរាជធានីភ្នំពេញ សម្រាប់បេក្ខជន បេក្ខនារី មកពី រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តពោធិ៍សាត់ ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តបាត់ដំបង និងខេត្តប៉ៃលិន។

-មណ្ឌលខេត្តព្រះសីហនុ សម្រាប់បេក្ខជន បេក្ខនារី មកពីខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត និងខេត្តកែប

-មណ្ឌលខេត្តស្វាយរៀង សម្រាប់បេក្ខជន បេក្ខនារី មកពីខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី

-មណ្ឌលនីមួយៗ ត្រូវជ្រើសរើសបេក្ខជនចំនួន ០៤រូប និងបេក្ខនារីចំនួន ០៤រូប ដើម្បីទៅវគ្គផ្តាច់ព្រ័ត្រ។

**៣. វគ្គប្រឡងផ្តាច់ព្រ័ត្រ** នឹងប្រព្រឹត្តទៅនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោង ១៧:០០នាទី នៅស្ថានីយទូរទស្សន៍អ៊ីធីវី (ETV) ស្ទឹងយូ៉ស្ទឹងមានជ័យ (ផ្សាយបន្តផ្ទាល់)។

**៤. លក្ខណៈសម្បត្តិសម្រាប់បេក្ខជន បេក្ខនារី៖**

-ជាកម្មករ-កម្មការិនី កំពុងធ្វើការងារយ៉ាងតិចបីខែក្នុងវិស័យឧស្សាហកម្ម ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង និងវិស័យសេដ្ឋកិច្ចផ្សេងៗទៀត។

-មានកម្ពស់ចាប់ពី ១.៦២ម សម្រាប់បេក្ខជន និង១.៥៨ម សម្រាប់បេក្ខនារី និងមានអាយុចាប់ពី ១៨ឆ្នាំ ដល់៣០ឆ្នាំ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន បងប្អូនកម្មករនិយោជិត និយោជក អង្គការសហជីព មេត្តាជ្រាបជាព័ត៌មាន។

*រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧*